ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
ចូល
មកដល់ថ្ងៃទី៖ 12.6.25 ម៉ោង៖ 10:30
លេខ៖ 2352
អ្នកទទួល៖ ហត្ថលេខា
អ្នកប្រគល់៖ ហត្ថលេខា
បញ្ជូនទៅ៖

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៤ សសរ

# សេចក្តីសម្រេច
# ស្តីពី
# សមាសភាពនិងការរៀបចំនិងការប្រព្រឹត្តទៅ
# របស់គណៈកម្មាធិការមន្ទីរពិសោធន៍វិភាគម្ហូបអាហារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការដំឡើងនាយកដ្ឋានវាយតម្លៃទទួលស្គាល់ទៅជាអគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់នៃកម្ពុជា ចំណុះក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញអនុក្រឹត្យលេខ៣៣៧ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីលក្ខណវិនិច្ឆ័យនៃមន្ទីរពិសោធន៍យោងនិងមន្ទីរពិសោធន៍ផ្លូវការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច

**ប្រការ១ ._**

សេចក្តីសម្រេចនេះ កំណត់អំពីសមាសភាពនិងការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការមន្ទីរពិសោធន៍វិភាគម្ហូបអាហារ។

**ប្រការ២ ._**

គណៈកម្មាធិការនេះមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ប្រធាន |
| ២- | តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប | អនុប្រធាន |
| ៣- | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | អនុប្រធាន |
| ៤- | តំណាងក្រសួងពាណិជ្ជកម្ម ១រូប | អនុប្រធាន |
| ៥- | តំណាងក្រសួងសុខាភិបាល ១រូប | សមាជិក |
| ៦- | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| ៧- | តំណាងក្រសួងទេសចរណ៍ ១រូប | សមាជិក |
| ៨- | អគ្គនាយកវាយតម្លៃទទួលស្គាល់នៃកម្ពុជា | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការនេះ ត្រូវទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាមីពាក់ព័ន្ធ។

**ប្រការ៣ ._**

គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ៖

- ពិនិត្យនិងសម្រេចលើសំណើកំណត់មន្ទីរពិសោធន៍វិភាគម្ហូបអាហារយោង និង/ឬមន្ទីរពិសោធន៍វិភាគម្ហូបអាហារផ្លូវការ យោងតាមរបាយការណ៍វាយតម្លៃ ដែលរៀបចំដោយលេខាធិការដ្ឋាន បន្ទាប់ពីទទួលបានអនុសាសន៍របស់ក្រុមអ្នកជំនាញមន្ទីរពិសោធន៍
- ផ្តល់ការគាំទ្រដើម្បីលើកកម្ពស់មន្ទីរពិសោធន៍វិភាគម្ហូបអាហារយោង និង/ឬមន្ទីរពិសោធន៍វិភាគម្ហូបអាហារផ្លូវការ ឱ្យក្លាយជាមន្ទីរពិសោធន៍ដែលមានសមត្ថភាពអនុលោមស្តង់ដាអន្តរជាតិ ISO/IEC 17025 និងជាមន្ទីរពិសោធន៍ដែលបានចូលរួមកម្មវិធីតេស្តវាស់វែងសមត្ថភាពមន្ទីរពិសោធន៍ពីមន្ទីរពិសោធន៍ជំនាញខ្ពស់ Proficiency Testing Program ( PTP ) ISO/IEC 17043
- ជំរុញឱ្យមានបណ្តាញទំនាក់ទំនងមន្ទីរពិសោធន៍វិភាគម្ហូបអាហារជាតិនិងអន្តរជាតិ
- សម្របសម្រួលក្នុងការចែករំលែក ប្រមូលផ្តុំព័ត៌មាន និងជំរុញការអភិវឌ្ឍជំនាញដល់មន្ទីរពិសោធន៍វិភាគម្ហូបអាហារទាំងអស់
- ជំរុញកិច្ចសហប្រតិបត្តិការក្នុងប្រទេស តំបន់ និងអន្តរជាតិពាក់ព័ន្ធនឹងមន្ទីរពិសោធន៍វិភាគម្ហូបអាហារ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូននាយករដ្ឋមន្ត្រី តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយករដ្ឋមន្ត្រី។

**ប្រការ៤ .-**

អនុប្រធាននិងសមាជិកគណៈកម្មាធិការនេះ ត្រូវចូលរួមការប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ករណីប្រធានអវត្តមាន អនុប្រធានមួយរូបអាចដឹកនាំកិច្ចប្រជុំ តាមការប្រគល់សិទ្ធិពីប្រធាន។

ការប្រជុំអាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាសភាពចូលរួមលើសពី៥០(ហាសិប)ភាគរយ។ សមាសភាពគណៈកម្មាធិការអវត្តមានពុំអាចឱ្យគេជំនួសបានឡើយ។ សេចក្ដីសម្រេចរបស់គណៈកម្មាធិការនេះ ត្រូវអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានគណៈកម្មាធិការ មានឧត្តមានុភាព។

គណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធនានា និងវិស័យឯកជន ចូលរួមពិគ្រោះយោបល់តាមការចាំបាច់។

**ប្រការ៥ .-**

គណៈកម្មាធិការនេះ អាចមានក្រុមការងារចំពោះកិច្ចនិងក្រុមអ្នកជំនាញមន្ទីរពិសោធន៍មួយចំនួន តាមការចាំបាច់ ដែលត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន។

**ប្រការ៦ .-**

គណៈកម្មាធិការនេះ មានអគ្គនាយកដ្ឋានវាយតម្លៃទទួលស្គាល់នៃកម្ពុជានៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាលេខាធិការដ្ឋានដើម្បីសម្របសម្រួលការងារ។

គណៈកម្មាធិការនេះ មានសិទ្ធិប្រើត្រារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការបំពេញការងាររបស់ខ្លួន។

**ប្រការ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ